ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
អគ្គលេខាធិការដ្ឋាន
លេខ ០០១ គ.ជ.ប/អគ្គ/ប្រ.ក.ព

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែមករា ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន

នៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៧ ជាថ្ងៃដំបូងនៃការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតតាមឃុំ សង្កាត់ ចាប់ផ្តើមបើកដំណើរការឱ្យប្រជាពលរដ្ឋដែលបានចុះឈ្មោះបោះឆ្នោតរួច ទៅពិនិត្យមើលឈ្មោះ និងផ្ទៀងផ្ទាត់ទិន្នន័យរបស់ខ្លួននៅឃុំ សង្កាត់ចំនួន ១៦៣៣ ទូទាំងប្រទេសកម្ពុជា។

១. ចំនួនឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង ដែលត្រូវបិទផ្សាយសរុប ៧,៨៦៤,៩២៩នាក់
២. ចំនួនឈ្មោះដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត សរុប ៨,៣៩៦នាក់
៣.ឈ្មោះដែលបានលុបចេញរួចហើយមានចំនួន ២,៧៣៧នាក់ ដោយសារទិន្នន័យនេះសល់ពីការចុះឈ្មោះសាកល្បង និងការផ្ទេរការិយាល័យក្នុងឃុំ សង្កាត់។

ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកដែលត្រូវលុបចេញពីបញ្ជីបោះឆ្នោត តាមឃុំ សង្កាត់នីមួយៗ ក្រៅពីមានការបិទផ្សាយនៅតាមសាលាឃុំ សង្កាត់ទាំង ១៦៣៣ ទូទាំងប្រទេសក៏មានបង្ហោះនៅលើគេហទំព័រ www.voterlist.org.kh ឬអាចហៅទូរស័ព្ទទៅកាន់លេខ **១២៨៥** ដើម្បីទទួលបានព័ត៌មានសម្រាប់ប្រព័ន្ធ Cell card, Smart និង Metfone ដោយឥតគិតថ្លៃផងដែរ ៕